**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ព្រឹទ្ធសភា រដ្ឋសភា ក្រុមប្រឹក្សាធម្មនុញ្ញ

លេខៈ ០១ ព.រ.ក

# សេចក្ដីសំរេចរួម
# ស្ដីពី
# បៀវត្សមូលដ្ឋាន និង ប្រាក់បំណាច់ផ្សេងៗ របស់មន្ត្រីរាជការ នៃក្រុមនីតិបញ្ញត្តិ

**ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា**

**ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា**

**ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញបទបញ្ជាផ្ទៃក្នុងនៃព្រឹទ្ធសភា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩៩ ស្ដីពីការតែងតាំងប្រធាន អនុប្រធានទី១ និង អនុប្រធានទី២ នៃព្រឹទ្ធសភាសំរាប់នីតិកាលទី១
- បានឃើញបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា
- បានឃើញកំណត់ហេតុសម័យប្រជុំពេញអង្គរដ្ឋសភាលើកទី១ នីតិកាលទី៣ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការបោះឆ្នោតជ្រើសតាំងប្រធាន អនុប្រធានទី១ និង អនុប្រធានទី២ នៃរដ្ឋសភាសំរាប់នីតិកាលទី៣
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៤/២២១ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងប្រធានក្រុមប្រឹក្សាធម្មនុញ្ញ សំរាប់អាណត្តិ៣ឆ្នាំ លើកទី៣
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៣/០០៧ ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០៣ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីលក្ខន្តិកៈមន្ត្រីរាជការ នៃក្រុមនីតិបញ្ញត្តិ
- យោងតាមការចាំបាច់ក្នុងការរៀបចំបៀវត្សមូលដ្ឋាន និង ប្រាក់បំណាច់ផ្សេងៗរបស់មន្ត្រីរាជការ នៃក្រុមនីតិបញ្ញត្តិ

# សំ រេ ច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ :**

បៀវត្សមូលដ្ឋាន និង ប្រាក់បំណាច់ផ្សេងៗ គឺជាកំរៃជីវភាពប្រចាំខែ ដែលរដ្ឋត្រូវផ្តល់ជូនមន្ត្រីរាជការស្ថិតនៅក្រោមការគ្រប់គ្រងនៃច្បាប់ ស្តីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ ក្នុងការបំពេញការងារ ។

បៀវត្សមូលដ្ឋាន និង ប្រាក់បំណាច់ផ្សេងៗរួមមាន :

- បៀវត្សមូលដ្ឋាន
- ប្រាក់បំណាច់មុខងារ
- ប្រាក់បំប៉នផ្គត់ផ្គង់ជីវភាពផ្សេងៗ
- ប្រាក់បំណាច់ទទួលខុសត្រូវ
- ប្រាក់ហានិភ័យ និង ប្រាក់វិភាជន៍គ្រួសារ ។

## ជំពូកទី២
## បៀវត្សមូលដ្ឋាន

**មាត្រា២ :**

បៀវត្សមូលដ្ឋាន គឺជាប្រាក់ប្រចាំខែ ដែលត្រូវផ្តល់ជូនមន្ត្រីរាជការសំរាប់ជីវភាពរស់នៅក្នុងនោះមាន : គ្រឿងឧបភោគ បរិភោគ ការស្នាក់នៅ សំលៀកបំពាក់ ការព្យាបាលជំងឺ ។

**មាត្រា៣ :**

បៀវត្សមូលដ្ឋាននៃមន្ត្រីរាជការត្រូវបែងចែកទៅតាមប្រភេទ ឋានន្តរស័ក្តិ និង ថ្នាក់ដែលត្រូវកំណត់ទៅតាមកំរិតនៃសន្ទស្សន៍ដូចខាងក្រោម :

| ប្រ.គ | ឋានន្តរស័ក្តិ | ថ្នាក់ | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ១៤ | ១៣ | ១២ | ១១ | ១០ | ៩ | ៨ | ៧ | ៦ | ៥ | ៤ | ៣ | ២ | ១ |
| ក | ក ១ | | | | | | | | | ៤៣៦ | ៤៩៧ | ៤៨២ | ៥០៦ | ៥២៨ | ៥៥០ |
| | ក ២ | | | | | ៣៦១ | ៣៧៣ | ៣៨៧ | ៤០២ | ៤១៥ | ៤៣៧ | ៤៥៥ | ៤៦៧ | ៤៧៨ | ៤៨៧ |
| | ក ៣ | ៣១៥ | ៣២៣ | ៣៣១ | ៣៤០ | ៣៤៩ | ៣៥៩ | ៣៦៩ | ៣៨០ | ៣៩០ | ៣៩៩ | ៤០៧ | ៤១៤ | ៤២០ | ៤២៥ |
| ខ | ខ ១ | | | | | | | | | ៣០៨ | ៣២៤ | ៣៤៤ | ៣៦០ | ៣៧៤ | ៣៨៥ |
| | ខ ២ | | | | | ២៥២ | ២៦២ | ២៧២ | ២៨៣ | ២៩៥ | ៣០៦ | ៣១៦ | ៣២៥ | ៣៣៣ | ៣៤០ |
| | ខ ៣ | ២២០ | ២២៥ | ២៣០ | ២៣៦ | ២៤៣ | ២៥១ | ២៥៩ | ២៦៦ | ២៧៣ | ២៧៩ | ២៨៤ | ២៨៩ | ២៩៣ | ២៩៧ |
| គ | គ ១ | | | | | | | | | ២១២ | ២២៣ | ២៣៥ | ២៤៥ | ២៥៤ | ២៦២ |
| | គ ២ | | | | | ១៧៣ | ១៧៨ | ១៨៥ | ១៩៣ | ២០១ | ២០៨ | ២១៥ | ២២២ | ២២៨ | ២៣៣ |
| | គ ៣ | ១៥០ | ១៥៤ | ១៥៨ | ១៦៣ | ១៦៨ | ១៧៤ | ១៧៩ | ១៨៤ | ១៨៨ | ១៩២ | ១៩៥ | ១៩៨ | ២០០ | ២០២ |
| ឃ | ឃ ១ | | | | | | | | | ១៤១ | ១៤៥ | ១៥៧ | ១៦៤ | ១៧០ | ១៧៥ |
| | ឃ ២ | | | | | ១១៣ | ១១៧ | ១២២ | ១២៨ | ១៣៤ | ១៣៩ | ១៤៤ | ១៤៨ | ១៥២ | ១៥៥ |
| | ឃ ៣ | ១០០ | ១០២ | ១០៤ | ១០៦ | ១០៩ | ១១២ | ១១៦ | ១២០ | ១២៣ | ១២៦ | ១២៩ | ១៣១ | ១៣៣ | ១៣៥ |

**មាត្រា៤ :**

តម្លៃឯកតានៃសន្ទស្សន៍សំរាប់អនុវត្តក្នុងតារាងបៀវត្សមន្ត្រីរាជការក្របខ័ណ្ឌនៃក្រុមនីតិប្បញ្ញត្តិមានចំនួន ៣០០៛ (បីរយរៀលគត់) ។ ការកែប្រែតំលៃឯកតានៃសន្ទស្សន៍នេះ ត្រូវធ្វើឡើងដោយសេចក្តីសំរេចរួមរបស់ប្រធានស្ថាប័នទាំងបី ។

**មាត្រា៥ :**

មន្ត្រីកម្មសិក្សាដែលជ្រើសរើសចេញពី សិស្ស និស្សិត ត្រូវបានផ្តល់សន្ទស្សន៍បៀវត្សក្នុងថ្នាក់ទី១៤ នៃឋានន្តរស័ក្តិទី៣ របស់ក្របខ័ណ្ឌនីមួយៗ។

**មាត្រា៦ :**

មន្ត្រីរាជការមានសិទ្ធិទទួលបៀវត្សមូលដ្ឋានបានតែក្នុងល័ក្ខខ័ណ្ឌដូចខាងក្រោម :

១- កំពុងបំពេញសកម្មភាពការងារ

២- កំពុងផ្លាស់ប្តូរកន្លែងធ្វើការនៅក្នុង ឬ ក្រៅប្រទេស

៣- កំពុងធ្វើដំណើរទៅកាន់មុខតំណែង ឬ កំពុងវិលត្រឡប់មកវិញ

៤- កំពុងបំពេញកម្មសិក្សាវិជ្ជាជីវៈ ឬ បច្ចេកទេសតាមតម្រូវការរបស់រដ្ឋ

៥- កំពុងបំពេញកម្មសិក្សាជាដំបូង ដើម្បីតាំងស៊ប់ក្នុងក្របខ័ណ្ឌ។

**មាត្រា៧ :**

សិទ្ធិទទួលនូវបៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការ ត្រូវគិតចាប់ផ្តើមពីថ្ងៃចូលបំរើការងារជាស្ថាពរ ដែលទទួលស្គាល់ដោយប្រធានស្ថាប័នសាមី ហើយត្រូវជូនដំណឹងជាលាយល័ក្ខណ៍អក្សរដល់ក្រសួងស្ថាប័នមានសមត្ថកិច្ច។

**មាត្រា៨ :**

មន្ត្រីរាជការដែលឈប់សំរាកស្របតាមបទប្បញ្ញត្តិ នៃច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការនៃព្រះរាជាណាចក្រកម្ពុជា និង បទប្បញ្ញត្តិផ្សេងៗ ដែលនៅជាធរមាន មានសិទ្ធិទទួលបៀវត្សមូលដ្ឋាន និង ប្រាក់បំណាច់ផ្សេងៗ។

**មាត្រា៩ :**

បៀវត្សមូលដ្ឋាន និង ប្រាក់បំណាច់ផ្សេងៗ ត្រូវផ្តល់ជូនដល់មន្ត្រីរាជការដែលត្រូវចាត់អោយចូលរៀនវគ្គបណ្តុះបណ្តាលបំពាក់បំប៉នវិជ្ជាជីវៈ ឬ បច្ចេកទេសតាមតំរូវការរបស់រដ្ឋស្របតាមក្របខ័ណ្ឌរបស់សាមីខ្លួន។

**មាត្រា១០ :**

ការបញ្ឈប់ផ្តល់បៀវត្សមូលដ្ឋាន ត្រូវធ្វើទៅតាមកំណត់នៃសេចក្តីសំរេចរបស់ប្រធានស្ថាប័ន ក្នុងករណីដូចខាងក្រោមនេះ :

- មន្ត្រីរាជការសុំលាឈប់ពីការងារដោយមានការអនុញ្ញាត
- មន្ត្រីរាជការដែលត្រូវបណ្តេញចេញពីមុខតំណែង

- មន្ត្រីរាជការដែលទទួលមរណភាព
- មន្ត្រីរាជការដែលអវត្តមានគ្មានការអនុញ្ញាត ឬ ហួសរយៈពេលកំណត់
- មន្ត្រីរាជការដែលវិលត្រឡប់មកកាន់ការងារវិញ ហួសរយៈពេលដែលកំណត់ដោយលិខិតបង្គាប់ការ លើកលែងតែករណីស្របច្បាប់ ដែលបញ្ជាក់ដោយអាជ្ញាធរមានសមត្ថកិច្ច
- មន្ត្រីរាជការដែលអវត្តមានហួសកាលកំណត់ក្នុងបេសកកម្ម ឬ ការឈប់សំរាក លើកលែងតែករណី ប្រធានស័ក្តិ ឬ ដោយជម្ងឺ ដែលមានលិខិតបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច ឬ ពីសមត្ថកិច្ចសុខាភិបាល
- មន្ត្រីរាជការដែលមានសាលក្រមរបស់តុលាការបញ្ជាក់ថាជាទណ្ឌិត ។

**មាត្រា១១ :**

មន្ត្រីរាជការដែលត្រូវបានដាក់អោយស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សគ្មានសិទ្ធិទទួលបៀវត្សមូលដ្ឋាន ចាប់ពីថ្ងៃកំណត់ដែលមានចែងក្នុងព្រះរាជក្រឹត្យ ឬ សេចក្តីសំរេច ។

**មាត្រា១២ :**

មន្ត្រីរាជការដែលត្រូវបានដាក់អោយចូលនិវត្តន៏ គ្មានសិទ្ធិទទួលបៀវត្សមូលដ្ឋានទេ ។

## ជំពូកទី៣

## ប្រាក់បំណាច់មុខងារ

**មាត្រា១៣ :**

ប្រាក់បំណាច់មុខងារ គឺជាប្រាក់បន្ថែមទៅលើបៀវត្សមូលដ្ឋានប្រចាំខែ ដែលត្រូវផ្តល់ជូនមន្ត្រីរាជការនៅក្នុងប្រភេទ **ក.ខ.គ** និង **ឃ** ហើយដែលកំពុងបំពេញមុខងារក្នុងស្ថាប័ន ។

**មាត្រា១៤ :**

ប្រាក់បំណាច់មុខងារត្រូវបានបែងចែកជា ០៥កំរិត ទៅតាមរយៈពេល និង បទពិសោធន៏ការងារក្នុងមុខតំណែងនីមួយៗ ដូចខាងក្រោម :

- កំរិតទី ៥ សំរាប់បទពិសោធន៏រយៈពេលក្រោម ០៣ឆ្នាំ
- កំរិតទី ៤ សំរាប់បទពិសោធន៏រយៈពេលពី ០៣ឆ្នាំ ទៅ ០៦ឆ្នាំ

- កំរិតទី ៣ សំរាប់បទពិសោធន៍រយៈពេលពី ០៦ឆ្នាំ ទៅ ១០ឆ្នាំ
- កំរិតទី ២ សំរាប់បទពិសោធន៍រយៈពេលពី ១០ឆ្នាំ ទៅ ១៦ឆ្នាំ
- កំរិតទី ១ សំរាប់បទពិសោធន៍រយៈពេលលើសពី ១៦ឆ្នាំ

**មាត្រា១៥ :**

ការផ្លាស់ប្តូរកំរិត និង ការផ្តល់ប្រាក់បំណាច់មុខងារ មិនអាចអនុវត្តទៅតាមឆ្នាំកំណត់ដូចមានចែងនៅក្នុងមាត្រា១៤ ជាស្វ័យប្រវត្តិបានទេ គឺត្រូវធ្វើឡើងដោយការវាយតម្លៃពីគណៈកម្មការតំលើងថ្នាក់ និង មានការយល់ព្រមពីប្រធានស្ថាប័ន។

**មាត្រា១៦ :**

មន្ត្រីរាជការដែលមានមុខតំណែងដូចខាងក្រោម ត្រូវបានទទួលប្រាក់បំណាច់មុខងារប្រចាំខែ ដូចមានចែងនៅក្នុងតារាងខាងក្រោមនេះ :

| ល.រ | មុខងារ | កំរិតទី ៥ | កំរិតទី ៤ | កំរិតទី ៣ | កំរិតទី ២ | កំរិតទី ១ |
|---|---|---|---|---|---|---|
| ០១ | អគ្គនាយក | ៧៣៥.០០០៛០០ | ៧៧៩.០០០៛០០ | ៨២៦.០០០៛០០ | ៨៧៦.០០០៛០០ | ៩២៩.០០០៛០០ |
| ០២ | អគ្គាធិការ | ៧២០.០០០៛០០ | ៧៦៣.០០០៛០០ | ៨០៩.០០០៛០០ | ៨៥៨.០០០៛០០ | ៩១០.០០០៛០០ |
| ០៣ | អគ្គនាយករង | ៦៤៥.០០០៛០០ | ៦៨៤.០០០៛០០ | ៧២៥.០០០៛០០ | ៧៦៩.០០០៛០០ | ៨១៥.០០០៛០០ |
| ០៤ | អគ្គាធិការរង | ៦៣០.០០០៛០០ | ៦៦៨.០០០៛០០ | ៧០៨.០០០៛០០ | ៧៥១.០០០៛០០ | ៧៩៦.០០០៛០០ |
| ០៥ | ប្រធាននាយកដ្ឋាន | ៦២០.០០០៛០០ | ៦៥៨.០០០៛០០ | ៦៩៨.០០០៛០០ | ៧៤១.០០០៛០០ | ៧៨៦.០០០៛០០ |
| ០៦ | អនុប្រធាននាយកដ្ឋាន | ៥០០.០០០៛០០ | ៥៣៨.០០០៛០០ | ៥៧៨.០០០៛០០ | ៦២១.០០០៛០០ | ៦៦៦.០០០៛០០ |
| ០៧ | មន្ត្រីអភិបាល | ៤០០.០០០៛០០ | ៤៣៨.០០០៛០០ | ៤៧៨.០០០៛០០ | ៥២១.០០០៛០០ | ៥៦៦.០០០៛០០ |
| ០៨ | ប្រធានការិយាល័យ | ៤៥០.០០០៛០០ | ៤៨៨.០០០៛០០ | ៥២៨.០០០៛០០ | ៥៧១.០០០៛០០ | ៦១៦.០០០៛០០ |
| ០៩ | អនុប្រធានការិយាល័យ | ៤០០.០០០៛០០ | ៤៣៨.០០០៛០០ | ៤៧៨.០០០៛០០ | ៥២១.០០០៛០០ | ៥៦៦.០០០៛០០ |
| ១០ | ប្រធានផ្នែក | ៣៥០.០០០៛០០ | ៣៨៨.០០០៛០០ | ៤២៨.០០០៛០០ | ៤៧១.០០០៛០០ | ៥១៦.០០០៛០០ |
| ១១ | មន្ត្រីឧបការី | ៣២០.០០០៛០០ | ៣៥៨.០០០៛០០ | ៣៩៨.០០០៛០០ | ៤២១.០០០៛០០ | ៤៦៦.០០០៛០០ |
| ១២ | មន្ត្រីលេខាធិការ | ២៦០.០០០៛០០ | ២៩៨.០០០៛០០ | ៣៣៨.០០០៛០០ | ៣៧១.០០០៛០០ | ៤១៦.០០០៛០០ |
| ១៣ | មន្ត្រីភ្នាក់ងារ | ២៣០.០០០៛០០ | ២៦៨.០០០៛០០ | ៣០៨.០០០៛០០ | ៣២១.០០០៛០០ | ៣៦៦.០០០៛០០ |

**មាត្រា១៧ :**

មន្ត្រីរាជការដែលស្ថិតនៅក្នុងមុខតំណែងណាមួយ ត្រូវទទួលប្រាក់បំណាច់មុខងារក្នុងមុខតំណែងនោះ ។

មន្ត្រីរាជការដែលកាន់មុខតំណែងច្រើន ត្រូវអនុញ្ញាតអោយជ្រើសរើសយកប្រាក់បំណាច់មុខងារតែមួយទេ ។

**មាត្រា១៨ :**

ការកែប្រែប្រាក់បំណាច់មុខងារ ត្រូវធ្វើឡើងដោយសេចក្តីសំរេចរួម ។

## ជំពូកទី ៤
## ប្រាក់បំប៉នផ្គត់ផ្គង់ជីវភាពផ្សេងៗ

**មាត្រា១៩ :**

មន្ត្រីរាជការដែលស្ថិតក្នុងក្របខ័ណ្ឌនៃក្រុមនីតិបញ្ញត្តិត្រូវបានទទួលប្រាក់បំប៉នផ្គត់ផ្គង់ជីវភាពផ្សេងៗ ប្រចាំខែចំនួន ២៥០.០០០៛០០ (ពីររយហាសិបពាន់រៀលគត់) ។

ការកែប្រែប្រាក់បំប៉នផ្គត់ផ្គង់ជីវភាពផ្សេងៗ ត្រូវធ្វើឡើងដោយសេចក្តីសំរេចរួម ។

## ជំពូកទី៥
## ប្រាក់បំណាច់ទទួលខុសត្រូវ

**មាត្រា២០ :**

ប្រាក់បំណាច់ទទួលខុសត្រូវ ជាប្រាក់បំណាច់បន្ថែមប្រចាំខែសំរាប់ផ្តល់ជូនមន្ត្រីរាជការ ដែលមានការតែងតាំងឋានៈ និង មានតួនាទីដឹកនាំក្នុងមុខតំណែងពិតប្រាកដ ។

**មាត្រា២១ :**

មន្ត្រីរាជការចាប់ពីឋានៈអគ្គនាយកចុះមកដល់ប្រធានផ្នែក ត្រូវបានទទួលប្រាក់បំណាច់ទទួលខុសត្រូវបន្ថែមដូចមានចែងនៅក្នុងតារាងខាងក្រោមនេះ :

| ល.រ | មុខងារ | ចំនួនទឹកប្រាក់ |
|---|---|---|
| ០១ | អគ្គនាយក | ២៦១.០០០៛០០ |
| ០២ | អគ្គាធិការ | ២៥១.០០០៛០០ |
| ០៣ | អគ្គនាយករង | ២៤១.០០០៛០០ |
| ០៤ | អគ្គាធិការរង | ២៣១.០០០៛០០ |
| ០៥ | ប្រធាននាយកដ្ឋាន | ២២១.០០០៛០០ |
| ០៦ | អនុប្រធាននាយកដ្ឋាន | ២០១.០០០៛០០ |
| ០៧ | ប្រធានការិយាល័យ | ១៨០.០០០៛០០ |
| ០៨ | អនុប្រធានការិយាល័យ | ១៦០.០០០៛០០ |
| ០៩ | ប្រធានផ្នែក | ១៤០.០០០៛០០ |

**មាត្រា២២ :**

ការកែប្រែប្រាក់បំណាច់ទទួលខុសត្រូវ ត្រូវធ្វើឡើងដោយសេចក្តីសំរេចរួម ។

**មាត្រា២៣ :**

មន្ត្រីដែលត្រូវបានតែងតាំងអោយមានឋានៈស្មើ គ្មានសិទ្ធិទទួលប្រាក់បំណាច់ទទួលខុសត្រូវឡើយ លើកលែងតែក្នុងករណីដែលសាមីជនបំពេញមុខការពិសេសចាំបាច់ ហើយសំរេចដោយប្រធានស្ថាប័នតាមសំណើរបស់អគ្គលេខាធិការ ។

## ជំពូកទី៦
## ប្រាក់ហានិភ័យ

**មាត្រា២៤ :**

ប្រាក់ហានិភ័យ គឺជាប្រាក់ប្រចាំខែសំរាប់ផ្តល់ជូនដល់មន្ត្រីរាជការទាំងឡាយដែលត្រូវអោយទៅបំរើការងារ ឬ បំរើការងារនៅក្នុងមុខងារ ឬ ទីកន្លែងដែលមានគ្រោះថ្នាក់ ជម្ងឺឆ្លង ការងារប៉ះពាល់សុខភាព ដូចជាកន្លែងក្តៅ សើម មានធូលីច្រើន ចំហាយជាតិពុល ឬ ជាតិគីមី សម្លេងខ្លាំងខ្លាំង ក្លិនស្អុយ និង តំបន់គ្រុនចាញ់ ។

**មាត្រា២៥ :**

ប្រាក់ហានិភ័យមានពីរគឺ :

១- ប្រាក់ប៉ះពាល់សុខភាព

២- ប្រាក់តំបន់

មុខងារដែលប៉ះពាល់សុខភាព និង តំបន់ហានិភ័យព្រមទាំងប្រាក់ហានិភ័យនឹងត្រូវកំណត់ដោយសេចក្តីសំរេចរួមមួយដោយឡែក ។

## ជំពូកទី៧
## ប្រាក់វិភាជន៍គ្រួសារ

**មាត្រា២៦ :**

ប្រាក់វិភាជន៍គ្រួសារ គឺជាប្រាក់ប្រចាំខែដែលត្រូវផ្តល់ជូនមន្ត្រីរាជការជាមេគ្រួសារ សំរាប់ប្រពន្ធ និង កូនស្របច្បាប់ នៅក្នុងបន្ទុក ។

ប្រាក់វិភាជន៍សំរាប់កូនអាចបន្តផ្តល់ជូនរហូតដល់អាយុ ២១ឆ្នាំ ក្នុងករណីមានលិខិតបញ្ជាក់ការសិក្សា ។

**មាត្រា២៧ :**

ប្រាក់វិភាជន៍គ្រួសារ ត្រូវផ្តល់ជូនមន្ត្រីរាជការនៅក្នុងគ្រប់ករណី ដែលសាមីខ្លួននៅមានសិទ្ធិទទួលបៀវត្សមូលដ្ឋាន ។

មន្ត្រីរាជការដែលជាមេគ្រួសារ ត្រូវទទួលខុសត្រូវចំពោះព័ត៌មានស្តីពីស្ថានភាពគ្រួសារ ទាក់ទងនឹងប្រាក់វិភាជន៍គ្រួសារ ។

**មាត្រា២៨ :**

ប្រាក់វិភាជន៍គ្រួសារប្រចាំខែត្រូវផ្តល់ជូនដូចខាងក្រោម :

| ល.រ | ប្រាក់វិភាជន៍គ្រួសារ | ចំនួនទឹកប្រាក់ |
|---|---|---|
| ០១ | ប្រពន្ធ | ៣.០០០រៀល |
| ០២ | កូន | ២.៥០០រៀល |

**មាត្រា២៩ :**

ការកែប្រែប្រាក់វិភាជន៍គ្រួសារ ត្រូវកំណត់ដោយសេចក្តីសំរេចរួម ។

## ជំពូកទី៨

## អវសានប្បញ្ញត្តិ

**មាត្រា៣០ :**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសំរេចនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៣១ :**

អគ្គលេខាធិការព្រឹទ្ធសភា អគ្គលេខាធិការរដ្ឋសភា និង អគ្គលេខាធិការក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ ។

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៤

| ប្រធានព្រឹទ្ធសភា | ប្រធានរដ្ឋសភា | ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ |
|---|---|---|
| ហត្ថលេខា និងត្រា | ព្រះហស្ថលេខា និងត្រា | ហត្ថលេខា និងត្រា |
| ជា ស៊ីម | នរោត្តម រណឫទ្ធិ | ប៊ិន ឈិន |

លេខ: ៣៤៥ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៤

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សុខ ឥសាន**

**កន្លែងទទួល**

- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការព្រឹទ្ធសភា
- អគ្គលេខាធិការរដ្ឋសភា
- អគ្គលេខាធិការក្រុមប្រឹក្សាធម្មនុញ្ញ
- ឯកសារ-កាលប្បវត្តិ